# សុន្ទរកថា
# សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងអធិការកិច្ច

ថ្ងៃអង្គារ ៤កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ គ្រិស្តសករាជ ២០២៤

- **ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល!**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីជាទីមេត្រី!**

ថ្ងៃនេះខ្ញុំមានសេចក្ដីរីករាយដែលបានចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងអធិការកិច្ច។ ខ្ញុំជឿជាក់ថា អស់រយៈពេលមួយថ្ងៃកន្លះមកនេះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងអធិការកិច្ច ពិតជាបានចូលរួមពិភាក្សា ផ្លាស់ប្ដូរយោបល់ និងឯកភាពគ្នាលើទិសដៅ និងអភិក្រមការងារសម្រាប់បំពេញបេសកកម្មជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តអភិក្រម **«ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់»** ដែល **សម្ដេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ** បានដាក់ចេញដើម្បីបន្តកែទម្រង់ស្ថាប័ន និងលើកកម្ពស់អភិបាលកិច្ចក្នុងវិស័យសាធារណៈ។

សន្និបាតនេះ គឺជាព្រឹត្តិការណ៍ប្រចាំឆ្នាំដ៏មានសារៈសំខាន់សម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងអធិការកិច្ច ដើម្បីពិនិត្យមើលឡើងវិញនូវលទ្ធផលការងារដែលក្រសួងសម្រេចបាននៅឆ្នាំមុនៗ និងស្វែងយល់កាន់តែច្បាស់និងលើកកម្ពស់ការចូលរួមអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅនូវវិស័យអធិការកិច្ច សំដៅជំរុញវិស័យនេះឱ្យឆ្លើយតបបានកាន់តែប្រសើរ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងទាន់ពេលទៅនឹងការវិវឌ្ឍនៃស្ថានភាពនយោបាយ សង្គម និងសេដ្ឋកិច្ច ទាំងនៅកម្ពុជា តំបន់ និងសកល។

ផ្អែកតាមរបាយការណ៍ **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងអធិការកិច្ច ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលការងារដែលក្រសួងសម្រេចបាននៅឆ្នាំ២០២៣ កន្លងទៅ។ ជាការពិត ជោគជ័យទាំងនេះមិនមែនកើតឡើងដោយចៃដន្យនោះទេ ប៉ុន្តែវាកើតចេញពីការខិតខំប្រឹងប្រែងរួមគ្នាឥតឈប់ឈរប្រកបដោយភាពម៉ឺងម៉ាត់ ប្រាកដនិយម ក្នុងស្មារតីសាមគ្គីភាព ឯកភាពផ្ទៃក្នុង និងកិច្ចសហការរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងអធិការកិច្ច។ ឈរលើស្មារតីល្អនេះ ខ្ញុំសូមលើកទឹកចិត្តឱ្យរួមគ្នាបន្តរៀបចំ និងអនុវត្តផែនការថ្មីៗ ប្រកបដោយសង្គតិភាពជាមួយគោលដៅនៃវិស័យអធិការកិច្ច សំដៅបន្តលើកកម្ពស់ការងារអធិការកិច្ច និងជំរុញការចូលរួមឱ្យកាន់តែសកម្មខ្លាំងបន្ថែមទៀតពីគ្រប់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្រេចបាននូវចក្ខុវិស័យអភិបាលកិច្ច និងស្ថាប័នល្អ និងមានគុណភាពខ្ពស់នៅកម្ពុជា។

ខ្ញុំក៏សូមឆ្លៀតយកឱកាសនេះសម្តែងនូវការថ្លែងអំណរគុណចំពោះ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងជាឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ** ដែលបានខិតខំយកចិត្តទុកដាក់នៅក្នុងការបំពេញមុខងារជាសេនាធិការជូនរាជរដ្ឋាភិបាល រហូតសម្រេចបាននូវលទ្ធផលការងារគួរជាទីមោទនៈក្នុងវិស័យអធិការកិច្ចកន្លងទៅនេះ ហើយក៏ជាមូលដ្ឋានសម្រាប់ការកសាងបន្តនៅអាណត្តិទី៧នេះ។

- **ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធី!**

សមិទ្ធផលដ៏ត្រចះត្រចង់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា បានឆ្លុះបញ្ចាំងយ៉ាងប្រត្យក្សនៃភាពធន់ និងភាពរឹងមាំនៃវិស័យនយោបាយ សង្គម និងសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ក្រោមអគ្គមគ្គុទេសក៍ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងជាប្រធានគណបក្ស** ក្នុងរយៈពេលប្រមាណជាង ៤ទសវត្សរ៍កន្លងទៅនេះ ដោយបានកែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចកម្ពុជា ពីសេដ្ឋកិច្ចផែនការទៅជាសេដ្ឋកិច្ចទីផ្សារ ប្រែក្លាយកម្ពុជាដែលហែកហួរដោយសង្គ្រាមស៊ីវិលទៅជាប្រទេសដែលមានសុខសន្តិភាព និងសុវត្ថិភាពពេញលេញ។

ជាមួយនឹងឆន្ទៈសម្រេចឱ្យបាននូវចក្ខុវិស័យក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ** ដើម្បី **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** ដោយបន្តផ្តោតជាចម្បងលើរបៀបវារៈជានា **«ប្រសិទ្ធភាពសមិទ្ធកម្ម»** តាមរយៈការអនុវត្តអភិក្រម **«ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់»** និងអភិក្រម **«ជវភាពនៃប្រព័ន្ធតួអង្គតែមួយ»** ដោយផ្តោតសំខាន់លើការអភិវឌ្ឍស្ថាប័ន ការពង្រឹងអភិបាលកិច្ច និងការពង្រីកប្រសិទ្ធភាពការងារក្នុងវិស័យសាធារណៈ ដូចមានកំណត់ត្រង់ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។

ការប្តូរឈ្មោះ**ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** មកជា **ក្រសួងអធិការកិច្ច** នៅដើមអាណត្តិទី៧នេះ គឺបានឆ្លុះបញ្ចាំងនូវការងារស្នូលរបស់ក្រសួង និងជាការបញ្ជាក់នូវឆន្ទៈមោះមុត និងឥតងាករេរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈឱ្យប្រកបដោយសមត្ថភាព តម្លាភាព ប្រសិទ្ធភាព គណនេយ្យភាព និងភាពទំនើប។

ជាក់ស្តែង ក្នុងនីតិកាលកន្លងមក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានចូលរួមយ៉ាងសកម្មក្នុងការជំរុញការលើកកម្ពស់អភិបាលកិច្ច និងស្ថាប័ន តាមរយៈការងារអធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ និងការងារដោះស្រាយបណ្តឹង ដែលបានចូលរួមកែលម្អចំណុចខ្វះខាតរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពសាធារណៈនានាលើការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ សំដៅលើកកម្ពស់គណនេយ្យភាព ភាពស្អាតស្អំ ក៏ដូចជាប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈ។ ជាក់ស្តែង ក្រសួងបានដោះស្រាយបណ្តឹងពីគ្រប់មជ្ឈដ្ឋាន ជាពិសេស ការងារស៊ើបអង្កេតករណីបណ្តឹងពាក់ព័ន្ធនឹងទំនាស់ដីធ្លី ដោយប្រើយន្តការសម្របសម្រួលបញ្ចប់ទំនាស់ផ្អែកលើគោលការណ៍**«ឈ្នះ-ឈ្នះ»** ពោលគឺគូភាគីទទួលយកដោយពេញចិត្ត និងសន្សំសំចៃដែលមិនចាំបាច់ចាយលើសេវាមេធាវី។

- **ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធី!**

ខ្ញុំសូមគាំទ្រចំពោះការដាក់ចេញនូវផែនការអាទិភាពដ៏សំខាន់ទាំង ៤ របស់ក្រសួងអធិការកិច្ច ដែលរួមមាន ៖ **ទី១.**ការពង្រឹងសមត្ថភាពស្ថាប័ន **ទី២.**ការកសាងនិងអភិវឌ្ឍមូលធនមនុស្ស **ទី៣.**ការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៅក្នុងសមត្ថកិច្ចក្រសួង ដែលរាជរដ្ឋាភិបាលបានប្រគល់ជូន និង **ទី៤.**ការថែរក្សាបរិយាកាសសុខដុមនីយកម្មនៅក្នុងក្រសួង និងអង្គភាពចំណុះទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ដើម្បីទទួលបានប្រសិទ្ធភាពលើការអនុវត្តកិច្ចការដ៏មានសារៈសំខាន់នេះ ខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនដល់ក្រសួងអធិការកិច្ចយកទៅអនុវត្តបន្ត ដូចខាងក្រោម៖

**ទី១-** ក្រសួងអធិការកិច្ច មានតួនាទីគន្លឹះក្នុងការជួយរាជរដ្ឋាភិបាលអនុវត្ត**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** សំដៅលើកកម្ពស់អភិបាលកិច្ច និងពង្រឹងភាពស្អាតស្អំ ក្នុងវិស័យសាធារណៈ ដោយផ្តោតអាទិភាពលើការពង្រឹងយន្តការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ ការផ្តល់ការលើកទឹកចិត្តផ្អែកលើគុណាធិបតេយ្យ និងការចាត់វិធានការ យ៉ាងម៉ឺងម៉ាត់តាមច្បាប់ក្នុងការដាក់ទណ្ឌកម្ម វិន័យ និងវិធានការច្បាប់ចំពោះមន្ត្រីសាធារណៈ ដែលប្រព្រឹត្តបំពានក្រមសីលធម៌វិជ្ជាជីវៈ ឬបំពានអំណាចនៅពេលអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន។

**ទី២-** ក្រសួងអធិការកិច្ចត្រូវផ្តួចផ្តើម និងនាំមុខនៅក្នុងការរៀបចំយន្តការត្រួតពិនិត្យប្រកបដោយគុណភាព ប្រសិទ្ធភាព ព្រមទាំងធានាបាននូវសុខដុមនីយកម្មនៃមុខងារអធិការកិច្ចនៅក្នុងរដ្ឋបាលសាធារណៈ។ ជាមួយគ្នានេះ ក្រសួងត្រូវយកចិត្តទុកដាក់ (១) ពង្រឹងទំនាក់ទំនង និងកិច្ចសហការល្អជាមួយអង្គភាពអធិការកិច្ចចំណុះឱ្យក្រសួង ស្ថាប័ន តាមរយៈការណែនាំឱ្យបានស៊ីជម្រៅលើការងារអធិការកិច្ច ការរៀបចំនីតិវិធី និងគំរូស្តង់ដារអធិការកិច្ចរួម ព្រមទាំងជួយបណ្តុះបណ្តាលជំនាញអធិការកិច្ចឱ្យបានទូលំទូលាយ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងសង្គតិភាពនៃការអនុវត្តការងារ (២) រួមគ្នាដោះស្រាយបញ្ហាប្រឈមនានាដែលបានកើតមានក្នុងវិស័យអធិការកិច្ច ដោយមានការចូលរួមពីក្រសួង ស្ថាប័ន និងអង្គភាពរងអធិការកិច្ច ដើម្បីបង្កើនប្រសិទ្ធភាពការងារ (៣) គោរពតាមឋានានុក្រមនៃការងារអធិការកិច្ច មានន័យថា ក្រសួងអធិការកិច្ចជាអធិការកិច្ចរាជរដ្ឋាភិបាល ធ្វើអធិការកិច្ចលើគ្រប់វិស័យនៅគ្រប់ក្រសួង

ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ចំណែកអគ្គាធិការដ្ឋានជាអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន និងធ្វើអធិការកិច្ចលើជំនាញក្នុងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នសាមី (៤) ចូលរួមក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្ដាប្រទេសដែលមានមុខងារត្រួតពិនិត្យ ដើម្បីលើកកម្ពស់មូលធនមនុស្ស ការផ្លាស់ប្ដូរបទពិសោធន៍ល្អៗ និងឧត្តមានុវត្តជាក់ស្ដែងពីគ្នាទៅវិញទៅមក និង (៥) បន្តផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយ សំដៅលើកស្ទួយការគោរព និងការអនុវត្តច្បាប់ កាត់បន្ថយអំពើពុករលួយ និងការរំលោភបំពានច្បាប់ លើកតម្កើងយុត្តិធម៌សង្គម ព្រមទាំងបង្កើតបាននូវវប្បធម៌សន្តិភាព អហិង្សា និងនីតិរដ្ឋ។

**ទី៣**- ក្រសួងអធិការកិច្ចត្រូវបន្តលើកកម្ពស់ និងពង្រឹងស្ថាប័នបន្ថែមទៀត ដោយផ្ដោតទៅលើ (១) ការកសាងមូលធនមនុស្ស ដោយពង្រឹងសមត្ថភាពមន្ត្រីឱ្យមានមនសិការ និងក្រមសីលធម៌វិជ្ជាជីវៈ ព្រមទាំងសមត្ថភាពស័ក្ដិសមជាទីពឹងរបស់ប្រជាពលរដ្ឋ (២) ពង្រឹងការអនុវត្តតួនាទីអធិការកិច្ចឱ្យបានទូលំទូលាយ ស្មើភាព និងមិនរើសអើងប្រកបដោយភាពទន់ភ្លន់តែម៉ឺងម៉ាត់ដោយផ្អែកលើច្បាប់ជាធំ តាមអភិក្រមទាំង៥ របស់ សម្ដេចតេជោ គឺ **«ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់»** (៣) ពង្រឹងយន្តការតាមដានការអនុវត្តច្បាប់ គោលនយោបាយ និងបទបញ្ជាដែលរាជរដ្ឋាភិបាលបានដាក់ចេញ ដើម្បីវាយតម្លៃការអនុវត្តគោលនយោបាយ វឌ្ឍនភាព និងសមិទ្ធកម្ម ធានាបានការបម្រើសេវាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងវិជ្ជាជីវៈ (៤) បន្តពង្រឹងយន្តការដោះស្រាយបណ្ដឹងរបស់ប្រជាពលរដ្ឋពីគ្រប់មជ្ឈដ្ឋាន ដោយរៀបចំវិធីសាស្ត្រងាយស្រួលសម្រាប់ទទួលពាក្យបណ្ដឹង តាមរយៈការបង្កើតការិយាល័យទទួលពាក្យបណ្ដឹងនៅតាមមន្ទីរអធិការកិច្ចរាជធានី ខេត្ត។ ជាមួយគ្នានេះ ក្រសួងអធិការកិច្ចត្រូវរៀបចំប្រព័ន្ធទទួលពាក្យបណ្ដឹងតាមប្រព័ន្ធអនឡាញ ដែលបង្កភាពងាយស្រួលដល់ការដាក់ពាក្យបណ្ដឹងទាន់ពេល និងឆាប់រហ័ស សំដៅបង្ខិតសេវានៃការដោះស្រាយវិវាទឱ្យកៀកជាមួយនឹងប្រជាពលរដ្ឋ។

**ទី៤**- ក្នុងទស្សនៈ **«អធិការកិច្ចដើម្បីទាំងអស់គ្នា ទាំងអស់គ្នាឆ្ពោះទៅកាន់អភិបាលកិច្ចល្អ»** ខ្ញុំសូមស្នើឱ្យគ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពសាធារណៈទាំងអស់ ត្រូវចូលរួមសហការឱ្យបានល្អក្នុងការងារអធិការកិច្ចដ៏មានសារៈសំខាន់នេះ ស្របតាមពាក្យស្លោករបស់ **សម្ដេចតេជោ «អធិការកិច្ចជាភ្នែក ជាត្រចៀករបស់ថ្នាក់លើ និងជាមិត្ត**

**ដ៏ជិតស្និទ្ធរបស់ថ្នាក់ក្រោម»** ដែលពាក្យស្លោកនេះត្រូវបានប្រើប្រាស់ជាបេសកកម្មរបស់ក្រសួងអធិការកិច្ចក៏ដូចជាបេសកកម្មរបស់អង្គភាពអធិការកិច្ចថ្នាក់ក្រោម ដើម្បីជួយថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់បានឃើញ និងបានឮ សម្រាប់យកមកពិចារណា ដោយស្ដាប់ឱ្យបានច្បាស់ សម្លឹងឱ្យឆ្ងាយ និងវិនិច្ឆ័យឱ្យបានត្រឹមត្រូវ។

**ទី៥-** ក្រសួងអធិការកិច្ច ត្រូវរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ សម្រាប់បម្រើឱ្យវិស័យអធិការកិច្ចឱ្យបានគ្រប់គ្រាន់ ជាពិសេសត្រូវពន្លឿនការតាក់តែងច្បាប់ អនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច ដោយសម្រួចលើការងារស្នូលសំខាន់ៗនៃការប្ដូរឈ្មោះក្រសួង និងសេចក្ដីព្រាងច្បាប់ស្ដីពីអធិការកិច្ចឱ្យបានឆាប់រហ័ស។ ទន្ទឹមនេះក្រសួងអធិការកិច្ចត្រូវសិក្សាលទ្ធភាពធ្វើវិសោធនកម្មច្បាប់ស្ដីពីបណ្ដឹងតវ៉ា និងច្បាប់ស្ដីពីបណ្ដឹងបរិហារ ដែលមានកន្លងមក ឬត្រូវតាក់តែងថ្មីឱ្យស្របតាមការវិវត្តនៃស្ថានភាពសង្គមជាតិជាក់ស្ដែង។ ខ្ញុំសូមឱ្យក្រសួងយុត្តិធម៌ និងក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្ដីការគណៈរដ្ឋមន្ត្រី និងក្រសួង ស្ថាប័នពាក់ព័ន្ធ សហការរៀបចំសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងអធិការកិច្ចឱ្យបានឆាប់រហ័ស ដោយឈរលើផល-ប្រយោជន៍រួម សំដៅឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់សង្គមជាតិ។

**ទី៦-** ក្រសួងអធិការកិច្ច ដែលមានវិទ្យាស្ថានជាតិអធិការកិច្ចជាសេនាធិការ ត្រូវពង្រឹងការអភិវឌ្ឍសមត្ថភាពមន្ត្រីអធិការកិច្ច ដោយយកចិត្តទុកដាក់ជ្រើសរើសមុខជំនាញ និងប្រមូលផ្ដុំគ្រូជំនាញមានបទពិសោធច្បាស់លាស់ទាំងទ្រឹស្ដី និងការអនុវត្ត ជាពិសេស ត្រូវជំរុញកិច្ចការស្រាវជ្រាវរបស់សិក្ខាកាមឱ្យមានលក្ខណៈវិទ្យាសាស្ត្រ និងអាចយកមកអនុវត្តស្របតាមបរិការណ៍នៃការអភិវឌ្ឍសង្គមជាតិ។ ទន្ទឹមនេះវិទ្យាស្ថានជាតិអធិការកិច្ច ត្រូវខិតខំអភិវឌ្ឍខ្លួនឱ្យមានសមត្ថភាពពេញលេញ និងគ្រប់គ្រាន់តាមជំនាញឯកទេសនីមួយៗឱ្យស្របនឹងតម្រូវការជាក់ស្ដែង សំដៅធ្វើឱ្យសិក្ខាកាមមានសមត្ថភាព និងជំនាញគ្រប់គ្រាន់ ដើម្បីបំពេញបាននូវតម្រូវការជំនាញជាសារវន្តរបស់ជាតិ។

**ទី៧-** ក្រសួងអធិការកិច្ចត្រូវសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ពង្រឹងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការរបស់ខ្លួន ជាពិសេស មន្ត្រីអធិការកិច្ចលើផ្នែកអក្ខរកម្មឌីជីថល (Digital literacy) ដើម្បីជំរុញការធ្វើបដិវត្តកម្មឌីជីថល និងធ្វើទំនើបកម្មស្ថាប័ន

សំដៅឈានទៅដល់ការសម្រេចអធិការកិច្ចដោយប្រើបច្ចេកវិទ្យាឌីជីថល ដែលការណ៍នេះម្យ៉ាងបង្កើនប្រសិទ្ធភាព កាត់បន្ថយពេលវេលា និងថ្លៃនៃការអនុវត្តការងារ និងម្យ៉ាងទៀតរួមចំណែកដល់គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ និងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-ឆ្នាំ២០៣៥។

- **ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

មុននឹងបញ្ចប់ ខ្ញុំសូមធ្វើការចំណាប់អារម្មណ៍បន្ថែមបន្តិចទៅលើកិច្ចការអធិការកិច្ចលើចំណុចមួយចំនួនដែលសំខាន់នៅក្នុងកិច្ចការងាររាជរដ្ឋាភិបាលអាណត្តិទី៧ នៅក្នុងយុទ្ធសាស្រ្តបញ្ចកោណក៏ដូចជាយុទ្ធសាស្រ្តចតុកោណ **កន្លងទៅស្នូលធំបំផុតគឺអភិបាលកិច្ច**។ អភិបាលកិច្ចបានន័យថាម៉ិច? រៀងចំផ្ទះខ្លួនយើងឱ្យស្អាតមុននឹងចេញទៅមើលផ្ទះគេ។ រៀបចំផ្ទះយើងឱ្យស្អាតទើបមានផាសុកភាពល្អ ទើបយើងអាចធ្វើការងារបម្រើប្រជាជនបានល្អ។ ទស្សនៈនេះត្រូវបន្ត ហើយកិច្ចការពីមួយអាណត្តិទៅមួយអាណត្តិ គឺបានធ្វើជាបន្តបន្ទាប់។ នៅក្នុងន័យនេះ ដូចក្នុងរបាយការណ៍បានគូសបញ្ជាក់ **ក្រសួងអធិការកិច្ចក៏បានដើរតួនាទីសំខាន់** ដែលយើងទើបតែបានប្តូរឈ្មោះ តែភារកិច្ចនៅតែបន្ត។ ការប្តូរឈ្មោះនេះ គឺបញ្ជាក់អំពីឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការសម្រួចភារកិច្ចរបស់ក្រសួងអធិការកិច្ច ដើម្បីដើរតួនាទីកាន់តែសកម្ម ជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការពង្រឹងកិច្ចការអភិបាលកិច្ចនេះ។ បើសិនជាការគ្រប់គ្រងរដ្ឋមិនអាចធ្វើទៅបានដោយប្រសិទ្ធភាពទេ សួរថាតើរដ្ឋទៅធ្វើការងារអ្វីបានបើគ្រប់គ្រងខ្លួនឯងមិនទាន់ច្បាស់លាស់? បើដៃជើងយើងមានច្រើន ប៉ុន្តែដៃជើងចេះតែដើរទៅជាន់ជើងគ្នាដួល ដើរទៅឆ្ងាយយ៉ាងណា? អញ្ចឹងការកំណែទម្រង់អធិការកិច្ចនិងស្ថាប័នរបស់ជាតិគឺជាកិច្ចការសំខាន់។ ការងារតាមដាន ត្រួតពិនិត្យ គឺជាគោលការណ៍ស្នូលសម្រាប់រាជរដ្ឋាភិបាលអាណត្តិទី៧ ដែលគោលការណ៍ស្នូលរបស់យើងគឺ ការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយទៅជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ។ ដើម្បីសម្រេចភារកិច្ចនេះ ការតាមដានការត្រួតពិនិត្យ ការសង្កេត ការស្រាវជ្រាវលើដំណើរការនៃការអនុវត្តការងារដើម្បីវាយតម្លៃលើការទទួលខុសត្រូវ និងវិនិច្ឆ័យរកគុណសម្បត្តិ គុណវិបត្តិ ដើម្បីធ្វើការកែលម្អឱ្យកាន់តែ

ប្រសើរជាការចាំបាច់ ហើយក្នុងនោះកិច្ចការអធិការកិច្ចគឺត្រូវធ្វើដោយមានប្រសិទ្ធភាពបំផុត និងប្រទាក់ក្រឡា។ នៅក្នុងរបាយការណ៍ **ឯកឧត្តម ហួត ហាក់** បានបញ្ជាក់ហើយក៏ដូចជាការលើកឡើងនៅក្នុងអង្គប្រជុំ គឺឮសូរអធិការកិច្ច គឺដឹងតែមកចាប់ គេច ធ្វើម៉េចឱ្យរួចខ្លួនសិន។ ខ្ញុំសូមបញ្ជាក់ថា អភិក្រមយើងទាំង៥ «ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់» ការងារអធិការកិច្ចគឺជួយអភិក្រមបួនខាងដើម។ ការងារពិនិត្យ ផ្តល់យោបល់ ឱ្យយើងអាចជួយឆ្លុះកញ្ចក់ខ្លួនឯងបាន ដែលខ្ញុំឧស្សាហ៍និយាយបើយើងឆ្លុះកញ្ចក់ យើងលួចមើលខ្នងយើងមិនឃើញ យើងមើលទៅឃើញមុខ ឃើញតែចំហៀង ដល់នៅខាងក្រោយផុតយើងមើលមិនឃើញ ត្រូវការស្ថាប័នជាមិត្ត ស្ថាប័នដៃគូ ដើម្បីជួយកាន់កញ្ចក់ក្រោយខ្នងហើយប្រាប់ថានៅកន្លែងនេះ។ អញ្ចឹង **ខ្ញុំសូមឱ្យអង្គភាព ស្ថាប័នទាំងអស់ កុំចាត់ទុកការងារអធិការកិច្ចគឺជាការងារចុះចាប់**។ អភិក្រម ៤ ដើម្បីឆ្លុះបញ្ចាំងនូវគុណសម្បត្តិ គុណវិបត្តិ។ សវនកម្មក៏ដូចគ្នា បន្តិចទៀតខ្ញុំនិយាដល់ចំណុចត្រូវកែទម្រង់ការងារសវនកម្ម និងអធិការកិច្ច ដើម្បីធ្វើ។ ឥឡូវយើងបង្កើតយន្តការតាមដានតាមសមិទ្ធកម្មផ្សេងៗនៅក្នុងក្រសួង ស្ថាប័ន បើយើងធ្វើកិច្ចការទាំងអស់នេះ ការងាររដ្ឋ ការអនុវត្តដូចប្រសាសន៍ **សម្តេចតេជោ** តាំងពីឆ្នាំប៉ែតជាងហើយកិច្ចការនេះខ្ញុំបានលើកជាច្រើនដងនៅក្នុងកងទ័ពដូចគ្នា ការធ្វើផែនការមិនខុសគ្នាទេ ទទួលបានបទបញ្ជាទៅថ្នាក់លើ រៀបចំផែនការ ផ្សព្វផ្សាយផែនការ ចាត់តាំងអនុវត្ត ហើយតាមដានត្រួតពិនិត្យ។ ការតាមដានត្រួតពិនិត្យនេះ គឺជាកត្តានៅក្នុងការធានានូវប្រសិទ្ធភាពការងារ ព្រោះផែនការរៀបចំមកកំណត់ទិសដៅ ត្រៀមសម្ភារៈមួយចំនួន ប៉ុន្តែចាប់ផ្តើមអនុវត្តហើយមិនដែលល្អតាមផែនការយើងទេ ជាពិសេស ស្ថានភាពដែលយើងធ្វើការវាយលុកហើយខាងម្ខាងទៀតក៏គេកែប្រែផែនការរបស់គេដែរ ដូចលេងអុកអញ្ចឹង អញ្ចឹងវាទាមទារឱ្យតាមការតាមដានត្រួតពិនិត្យវាយតម្លៃជាប់ជាប្រចាំ កិច្ចការអធិការកិច្ច សវនកម្ម ឥឡូវយើងមាន M&E ថែមទៀត ដើម្បីធ្វើយ៉ាងណាតាមដានត្រួតពិនិត្យ។ អញ្ចឹងកិច្ចការងារនេះគឺចាំបាច់ណាស់នៅក្នុងការបង្កើនប្រសិទ្ធភាព ហើយខ្ញុំសូមអរគុណណាស់ទៅដល់មន្ត្រីអធិការកិច្ច មន្ត្រីសវនកម្មថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ គ្រប់ក្រសួង ស្ថាប័នទាំងអស់ ទាំងផ្ទៃក្រៅផ្ទៃក្នុង ដែលបានដើរតួនាទីនៅក្នុងកិច្ចការនេះ។ ខ្ញុំដឹងហើយពាក្យថាសវនកម្ម ពាក្យថាអធិការកិច្ច ខ្ញុំនៅកងទ័ពក៏មិនខុសគ្នាដែរ ជួនកាលជិះតែឡានឆ្លងចូលគេថាមកធ្វើអី

អធិការកិច្ច ព្រោះអធិការកិច្ចភាគច្រើនធ្វើតាមពាក្យបណ្តឹង តាមចំណុចអីផ្សេងៗ ធ្វើការស្រាវជ្រាវ មិនមែនស្រាវជ្រាវដើម្បីកាត់ចោល ដើម្បីដេញចេញអីនោះទេ ដើម្បីបញ្ជាក់គេខ្លះក្នុងការកែសម្រួល។ អញ្ចឹងកិច្ចការនេះត្រូវមានប្រសិទ្ធិភាព ខ្ញុំផ្តោតកិច្ចការអធិការកិច្ចជាកិច្ចការសំខាន់ តែត្រូវមើលអធិការកិច្ចខ្លួនឯង ត្រូវមើលយន្តការអធិការកិច្ចរបស់រដ្ឋ ត្រូវពិនិត្យផ្ទះហ្នឹងប្រាកដជារៀបរយហើយឬនៅ? ថ្ងៃនេះខ្ញុំចូលរួមមតិយោបល់លើការងារនេះ ការពង្រឹងការងារអធិការកិច្ចជាការចាំបាច់ដើម្បីសម្រេចនូវអភិក្រមរបស់យើង ស្នូលនៃរដ្ឋាភិបាល ប្រសិទ្ធិភាព ស្អាតស្អំ និងភាពជឿទុកចិត្តរបស់ប្រជាពលរដ្ឋ។ អញ្ចឹងយន្តការតាមដានត្រួតពិនិត្យជាការសំខាន់។ ការងារអធិការកិច្ច ជាការងាស្មុគស្មាញ ហើយទាមទារនូវការកសាងសមត្ថភាព និងលក្ខណៈសម្បត្តិសំខាន់ៗ ក្នុងនោះសូមឱ្យពិនិត្យលើការងារ ៣ (ធនធានមនុស្ស យន្តការនិងរបៀបរបបការងារ និងលិខិតបទដ្ឋានគតិយុត្ត)។

ទី១- ធនធានមនុស្ស បានលើកឡើងនៅក្នុងរបាយការណ៍របស់ **ឯកឧត្តម ហួត ហាក់** ដែលបានលើកគឺការយកចិត្តទុកដាក់ក្នុងការកសាងមូលធនមនុស្ស នៅក្នុងវិស័យអធិការកិច្ច។ **ខ្ញុំសូមគាំទ្រ និងត្រូវធ្វើឱ្យខ្លាំង** ។ យើងទៅត្រួតពិនិត្យយ៉ាងម៉ិច បើយើងមិនខ្លាំងខ្លួនឯងមិនច្បាស់ខ្លួនឯង។ ខ្លាចបំផុតយកឯកសារត្រឹមត្រូវទៅឱ្យអ្នកមិនច្បាស់កែ។ អ្នកមិនច្បាស់ខ្លះគាត់មិនហ៊ាន តែអ្នកមិនច្បាស់ខ្លះហ៊ាន ហើយហ៊ានហ្នឹងរឹងណាស់គឺវាធ្វើឱ្យខូចការទាំងអស់ ទីបំផុតជំនាញមិនច្បាស់លាស់ គេធ្វើពីក្រោមច្បាស់លាស់ទៅដល់លើវាយតម្លៃខុស ។ ផ្អែកលើការងារមិនច្បាស់លាស់ធ្វើឱ្យថ្នាក់ក្រោមបាក់ទឹកចិត្ត ឬកែប្រព័ន្ធការងារពីច្បាស់លាស់ទៅមិនច្បាស់លាស់។ ហេតុនេះត្រូវទាមទារឱ្យមន្ត្រីអធិការកិច្ចនីមួយៗ ត្រូវមានធនធានមនុស្សដ៏ច្បាស់លាស់លើការងារនេះ ហើយត្រូវយកចិត្តទុកដាក់ឱ្យមែនទែន។ ព្រោះបើយើងមិនច្បាស់យើងឱ្យយោបល់អ្នកណា?កិច្ចការងារនេះត្រូវពង្រឹង ម៉ិញមានវិទ្យាស្ថានជាតិអធិការកិច្ចក៏ដូចជាតាមបណ្តាស្ថាប័នដើរតួ ហើយក្រសួង ស្ថាប័នត្រូវមានយន្តការ។

**ទី២-** យន្តការការងារ និងរបៀបរបបការងារ។ នេះគឺកិច្ចការធំ តាមខ្ញុំដឹងនាយកដ្ឋានខ្លះរបស់ក្រសួង ស្ថាប័ន ទាំងសវនកម្ម ទាំងអធិការកិច្ចផ្ទៃក្នុង ផ្ទៃក្រៅ ៧ដងលើការងារតែមួយក្នុងមួយឆ្នាំ ដោយស្ថាប័នខុសគ្នាទាំងក្រៅតែម្តងដែលផ្អែកលើបទដ្ឋានការងារខុសគ្នាទៀត យើងពេលខ្លះមានការលំបាកដែរ។ ឥឡូវនៅថ្នាក់ជាតិរបស់យើង ផ្នែកខាងក្រៅ មាន៤ស្ថាប័ន

ដែលធ្វើកិច្ចការងារនេះ មានអាជ្ញាធរសវនកម្មជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអធិការកិច្ច ក្រសួងមុខងារសាធារណៈ ដែលមានសិទ្ធិធ្វើសវនកម្ម និងអធិការកិច្ចលើគ្រប់ក្រសួង ស្ថាប័ន ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិរហូតដល់ខេត្ត។ កន្លងទៅយើងមានបញ្ហានេះច្រើន យើងខិតខំសម្របសម្រួលចេញអនុក្រឹត្យ១៦៨ ឆ្នាំ២០២០ យើងមានអនុក្រឹត្យលេខ៤០ ឆ្នាំ២០០៥ ហើយក្រោយមកកែ ២៦៥ ឆ្នាំ២០២៣ចុងឆ្នាំ ដើម្បីព្យាយាមធ្វើយ៉ាងណាសម្របសម្រួលកុំឱ្យត្រួតស៊ីគ្នាទៅលើកិច្ចការនេះ។ នេះជាទិសដៅត្រូវហើយ ប៉ុន្តែជាក់ស្តែងការអនុវត្តយើងមិនទាន់បានទេ អញ្ចឹងសូមយកអនុក្រឹត្យនេះធ្វើយ៉ាងណា ដើម្បីជំរុញពង្រឹងទៅលើកិច្ចការងារនេះ។ ហើយនៅក្នុងក្រសួង ស្ថាប័ន កាលពីមុនយើងមានសវនកម្មផ្ទៃក្នុង ហើយអធិការកិច្ចទៅ ឥឡូវយើងបង្កើតយន្តការតាមដានសមិទ្ធកម្មទៀត អញ្ចឹងតើ៣នេះចាំបាច់មានទាំង៣ ឬកន្លែងខ្លះវាជាន់គ្នាទៅហើយ។ អញ្ចឹងត្រួតនៅក្នុងក្រសួងមើលតាមនាយកដ្ឋាននីមួយៗ អញ្ចឹងបាននាយកដ្ឋានខ្លះអូឌីត ទាំងពីខាងក្នុងផង និងខាងក្រៅផង ចូល ៥ ៦ ៧ដង លើលើកិច្ចការតែមួយ។ អញ្ចឹង **ខ្ញុំសូមឱ្យពិនិត្យលើកិច្ចការងារនេះ ជាពិសេស ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូនព័ន្ធ មុនីរ័ត្ន ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការគោលនយោបាយសេដ្ឋកិច្ចហិរញ្ញវត្ថុ ដែលដឹកនាំធ្វើកន្លងទៅដឹកនាំទៅលើកិច្ចការនេះ។** យើងមានអនុក្រឹត្យលេខ១៦៨ ហើយធ្វើយ៉ាងម៉េចជំរុញការអនុវត្តឱ្យបានល្អ ព្រោះរឿងនេះដូចយើងអញ្ចឹងបើដើងយើងច្រើនដើរព័ន្ធតែគ្នាក៏ពិបាក ព័ន្ធដួលទៅ វាដួលទៅលើអង្គភាព យើងបានដំណើរការការងារនេះ២០ឆ្នាំហើយ។ យើងបានខិតខំកែសម្រួល អញ្ចឹងកិច្ចការងារនេះគឺធ្វើយ៉ាងណាដើម្បីយកចិត្តទុកដាក់អាចពិចារណា មើល? យើងមាន៤ស្ថាប័នថ្នាក់ជាតិ តើអាចមានរៀបចំជាយន្តការកំពូលណាមួយដើម្បីសម្របសម្រួលការអនុវត្តយន្តការនេះ? ឬមួយក៏ប្រគល់ភារកិច្ចឱ្យស្ថាប័នណាមួយដឹកនាំសម្រាប់តាមដានត្រួតពិនិត្យមើល? ព្រោះអនុក្រឹត្យចេញហើយ ប៉ុន្តែការអនុវត្តត្រូវមានអ្នកជួយមើលថែមទៀត បានន័យថា អធិការកិច្ចទៅមើលគេអនុវត្តត្រូវ ឬខុស? ប៉ុន្តែដល់ស្ថាប័នអធិការកិច្ចខ្លួនឯងមានអ្នកណាឆែកពីលើ? បើឆែកគេអត់មានអ្នកណាគេជួយប្រាប់យើងវិញថាយើងដើរព័ន្ធគ្នាហើយ ធ្វើអត់ទាន់ទេ អញ្ចឹងត្រូវគិតគូរអំពីក្របខណ្ឌមួយដែលសម្រាប់ជួយសម្របសម្រួលពីលើ ព្រោះថាមានឆែកតែគេ អត់មានអ្នកណាឆែកយើង?

អាហ្នឹង ហៅការត្រួតពិនិត្យគុណភាពគ្រប់ឋាន: Quality Control (QC) សូមឱ្យជួយពិនិត្យមើលលើការងារនោះ ដើម្បីសង្គតិភាព តែមានលើសពី១ គឺត្រូវមានយន្តការតាមដានត្រួតពិនិត្យ ការបែងចែកភារកិច្ច និងបែងចែកការទទួលខុសត្រូវ។ តាមអនុក្រឹត្យ១៦៨ នេះជាការល្អ ប៉ុន្តែជំរុញការអនុវត្តយើងត្រូវធ្វើនៅពេលអនុក្រឹត្យចេញ ហើយវាប្រទាក់ក្រឡាគ្នាយើងត្រូវកែសម្រួល អញ្ចឹងយើងត្រូវមានការតាមដាន ត្រួតពនិត្យ។ អាចពិនិត្យមើលប្រគល់ភារកិច្ច ឬមួយក៏គណៈកម្មការគោលនយោបាយជាតិមាន Task Bord មួយសម្រាប់តាមដានជួយសម្រួលទៅលើកិច្ចការនេះ។ ព្រោះថាយើងចង់ធ្វើយ៉ាងណាឱ្យផ្ទះរបស់យើងមានលំដាប់លំដោយរៀបរយលើកិច្ចការងារនេះ។ ព្រោះពេលដែលស្ថាប័នអធិការកិច្ច និងសវនកម្មរៀបរយ សហការគ្នាល្អ ប្រទាក់ក្រឡាល្អ គឺអាចជួយ គឺថារៀបចំជាស្តង់ដារដើម្បីអនុវត្តធ្វើសវនកម្ម អធិការកិច្ច គឺទៅមើលហ្នឹង មើលស្តង់ដារ ត្រូវឬខុស? ដើរខុសគន្លងឬយ៉ាងម៉េច? បើស្តង់ដារប្រទាក់ក្រឡាអត់ជាន់គ្នា វាពិបាក ហើយបើស្តង់ដារដូចគ្នាតែទៅមើលដល់ទៅ ៧ដង ហ្នឹងក៏លំបាក បានន័យថាយើងអត់ទុកចិត្តពីណាសោះ។ អញ្ចឹងត្រូវគិតគូរឡើងវិញទៅលើបញ្ហានេះ ហើយផ្ទៃក្នុងដូចគ្នា ជួនកាលយើងពិនិត្យមើលឡើងវិញ វាយតម្លៃឡើងវិញ ជាពិសេស ឆ្នាំ២០២៤ ដែលខ្ញុំថាយកជាឆ្នាំពង្រឹងស្ថាប័នទាំងមូល គ្រប់ស្ថាប័នឱ្យកែសម្រួលរចនាសម្ព័ន្ធ ផ្ទៃក្នុង អញ្ចឹងត្រូវមើលរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងយន្តការរបស់រដ្ឋាភិបាលក្នុងក្របខ័ណ្ឌ អន្តរក្រសួង អន្តរស្ថាប័ន។ បើមិនអញ្ចឹងទេយើងនៅតែបន្ត កន្លែងខ្លះខ្វះចន្លោះប្រហោង ហើយបើអញ្ចឹងប្រសិទ្ធភាពអត់មាន កន្លែងជាន់គឺជាន់ជើងគ្នា អត់សូវមានអ្នកទទួលខុសត្រូវ។ អញ្ចឹងកិច្ចការងារនេះ គឺជាកិច្ចការសំខាន់ពាក់ព័ន្ធទៅនឹងរឿងកិច្ចការការងារអធិការកិច្ច និង សវនកម្ម។

**ទី៣-** គឺក្របខ័ណ្ឌបទដ្ឋានគតិយុត្ត អញ្ចឹងសូមឱ្យសុំឱ្យពិនិត្យមើលការជំរុញការអនុវត្តស្របតាមអនុក្រឹត្យ ១៦៨ ២៦៥ ៤០ ពិនិត្យមើលទៅក្នុងយន្តការនេះឡើងវិញ បូកជាមួយនឹងការពិនិត្យជាក់ស្តែង តើវាស្របទៅតាមស្ថានភាពទេ? ឬមួយក៏មិនស្របអាចកែសម្រួល? ឥឡូវធ្វើម៉ិចរុញឱ្យវាដើរសិន និងបែងចែកភារកិច្ច (**ទី២**) ពិនិត្យមើលទៅយន្តការនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិមួយណាដែលជាន់គ្នាខ្លះ?ខ្ញុំលើកឧទាហរណ៍៣យន្តការនៅគ្រប់ក្រសួង ស្ថាប័ននីមួយៗមានសវនកម្មផ្ទៃក្នុង មានអធិការកិច្ចផ្ទៃក្នុង ហើយមាន

(M&E)។ តើសវនាកម្មផ្ទៃក្នុង (M&E) គឺតាមដានត្រួតពិនិត្យកិច្ចការផ្ដែកទៅលើសូចនាករ ស្រដៀងទៅនឹងសវនកម្មដែលធ្វើការជាអចិន្ត្រៃយ៍។ អធិការកិច្ច យើងពេលខ្លះ Sport Check យើងឆែកម្ដងម្កាលទៅតាមកិច្ចការ កន្លែងខ្លះយើងអាចក៏អាចធ្វើជាន់គ្នាដែរ។ ព្រោះថាវាច្រើន ទី១.ចំណាយធនធានមនុស្ស ទី២.អាចអន្សមផៅ អន្សមខ្លោច ហើយ ទី៣. ធ្វើឱ្យរំខាន ទៅដល់ស្ថាប័ន នាយកដ្ឋានផ្សេងៗ ចឹងដ៏ច្រើនពេកទៅនាំគ្នាគេច ទើបតែទៅមួយ ស្អែក មកទៀតហើយ ២ខែក្រោយមក ២ ៣ ទៀត។ គ្រឹះស្ថានសាធារណៈក៏មានឃើញដាក់សារ មកខ្ញុំជាប្រចាំដែរ សូមជួយពិនិត្យមើលលើរឿងហ្នឹងផង។ គ្រឹះស្ថានសាធារណៈរបស់រដ្ឋខ្លះ គាត់ដាក់មកហ្មង សម្ដេចជួយមើលផង ៥ ៦ដង។ ប៉ុន្តែកិច្ចការងារនេះរាជរដ្ឋាភិបាលយើង បានធ្វើការ ហើយយើងបង្កើតការបែងចែក ១៦៨ .... ប៉ុន្តែមិនទាន់អនុវត្ត អញ្ចឹងសុំពិនិត្យមើល។ **ទី២. គឺជំរុញច្បាប់ស្ដីពីអធិការកិច្ចឱ្យចេញពីឆ្នាំ២០២៤ ព្រោះច្បាប់នេះគឺជាគោលធំលើ ជំនាញអធិការកិច្ច** ។ ព្រោះថាជំនាញអធិការកិច្ចតាមស្ថាប័នអត់មានអីជាគោលរួមទេ គឺយក ផ្អែកទៅតាមជំនាញ កសិកម្មតាមច្បាប់កសិកម្មទៅ ខាងផ្សេងៗយកទៅ អញ្ចឹងអត់មាន អ្នកអនុវត្តហ្នឹងក៏រាងភ័យៗពោះ មិនដឹងមានស្អីជាគោលរៀបចំច្បាប់នេះជាគោល ព្រោះថា នៅក្រោយពីច្បាប់នេះចេញនឹងដោះស្រាយបញ្ហាបានច្រើន។ ការបែងចែកភារកិច្ច និងការ កំណត់ទិសដៅផ្សេងៗទៀត។ អញ្ចឹងគឺធ្វើម៉េចគឺរុញកិច្ចការងារនេះឱ្យបាន ឥឡូវគឺនៅជាប់ រឿងសង្គតិភាព តាមខ្ញុំដឹង គឺរឿងរៀបចំអនុក្រឹត្យស្ដីពីការដំណើរការរបស់ក្រសួងគឺត្រូវរុញ អាហ្នឹងលឿន ហើយរៀបចំច្បាប់នេះចេញឱ្យលឿន ដើម្បីយកអាហ្នឹងជាគោលសម្រាប់ ជំនាញអធិការកិច្ចធ្វើការ ហើយបើយើងមិនមើលខ្លួនឯង មើលស្ថាប័នដែលធ្វើអធិការកិច្ច សូម្បីតែខ្លួនយើងក៏នៅប្រទាក់ក្រឡាមិនទាន់ច្បាស់ហើយ អាហ្នឹងហើយដែលលំបាក។ អញ្ចឹង កិច្ចការងារនេះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ថ្ងៃអត់បានចូលស្អែក មានកម្មវិធីពីរថ្ងៃជាប់ គ្នា។ ខ្ញុំស្គាល់ ខ្ញុំមកសុខាក្នុងរយៈពេលប៉ុន្មានខែនេះចង់ច្រើនជាង ៦ ៧ឆ្នាំ នៅស្រុកខ្មែរ កម្មវិធីជាប់ស្អែកជួបគ្នានៅទីនេះទៀត។ គឺសូមពិនិត្យទៅលើកិច្ចការងារនេះ ហើយអធិការកិច្ច ដើរតួនាទីជាសេនាធិការក្នុងការពិនិត្យមើលកិច្ចការ ជួយជំរុញហើយនៅក្នុងនោះ គឺមានស្ថាប័ន ពាក់ព័ន្ធទាំងអស់ដែលបានចូលរួមទៅលើកិច្ចការនេះ។

**ទី៤-** គឺរបាយការណ៍របស់ **ឯកឧត្តម ហួត ហាក់** បានស្នើសុំតែម្ដង សុំការសហការ កុំរត់ កុំគេច កុំសម្រួលភារកិច្ចអ្នកជួយប្រាប់ គួរតែលើកទឹកចិត្តនៅក្នុងការការពារគាត់ ប្រាប់ត្រូវ ឬខុសត្រូវយកមកបញ្ជាក់ គោលដៅធំយកទៅមិនមែនដើម្បីអភិក្រមទី៥ វះកាត់ចោល ឱ្យតែប៉ះដៃកាត់ដៃ ប៉ះជើងកាត់ជើង នោះទេ យើងចង់ណាស់កែសម្រួល គ្មានពីណាល្អឥតខ្ចោះទេ ដែលជោគជ័យនោះ អភិក្រមបួន ងូតទឹក ឆ្លុះកញ្ចក់ ដុសក្អែល ព្យាបាល ត្រូវការផ្ដល់ព័ត៌មាន ដើម្បីជួយគ្នាពង្រឹងស្ថាប័ន ហើយរដ្ឋមន្ត្រី អភិបាលរាជធានី ខេត្ត កុំខ្លាចនៅក្នុងការទទួលនូវកិច្ចការងារនេះ ហើយនៅតាមក្រសួង ស្ថាប័នយុត្តិធម៌នីមួយៗខ្ញុំគិតថា គួរតែស្វាគមន៍ហើយលើកទឹកចិត្តក្នុងរូបភាពណាមួយ ដើម្បីយើងយកមកពង្រឹងខ្លួនឯងទេ។ នេះជាការជួយទៅដល់រដ្ឋមន្ត្រី ប្រធានស្ថាប័ន អភិបាលរាជធានី ខេត្ត ក្នុងការតាមដានត្រួតពិនិត្យនូវការអនុវត្តកិច្ចការរបស់ខ្លួន ដើម្បីយើងដាក់ផែនការកែសម្រួលភ្លាមៗ ដើម្បីឈ្នះសង្គ្រាម មេទ័ពដែលដាក់ផែនការហើយទៅដេកនៅក្នុងបន្ទាយអត់ទៅរួចទេ បើមិនតាមអាយកូមដាប់ តាមកែសម្រួលត្រូវការចល័យអីយ៉ាងម៉ិច? ចេញទៅខុសទិសដៅយ៉ាងម៉េច ត្រូវកែយ៉ាងណា? មេទ័ព ប្រធានស្ថាប័ន អភិបាលរាជធានី ខេត្ត ដែលកាន់កម្លាំង កាន់ស្ថាប័នទទួលខុសត្រូវ នៅជាប់ឱ្យមានសេនាធិការមួយ ដែលទទួលតាមដានការវិវត្តន៍នៃសមរភូមិ រួមជាមួយសេនាធិកាមួយទៀត តាមដានប្រមូលព័ត៌មាន វិភាគឱ្យយើងធ្វើការងារនេះ ដូចជា ក២ ក៣។ ក២ ប្រមូលការវិវត្តន៍ព័ត៌មានការប្រែប្រួលផ្សេងៗដើម្បីយើងរៀបចំកែសម្រួលផែនការ។ ផ្នែកអធិការកិច្ចផល់ព័តមានឱ្យយើងដើម្បីយើងរៀបចំកែសម្រួលផែនការដែលយើងចន្លោះប្រហោង។ ហើយ (M&E) ដូចជា ក៣ អញ្ចឹងប្រតិបត្តិការតាមការវិវត្តន៍ដល់ណាហើយ ខ្វះអីខ្លះ? អញ្ចឹងកិច្ចការទាំងអស់ ខ្ញុំសូមឱ្យមានការចូលរួមគាំទ្រពីស្ថាប័ននៅក្នុងការអនុវត្តផែនការអធិការកិច្ច ចូលរួមបង្កលក្ខណៈសហការ ផ្ដល់តម្លៃនូវលទ្ធផលដែលផ្ដល់ឱ្យសវនករ ទៅអធិការកិច្ច ឃើញហើយផ្ដល់យោបល់ថាចំណុចនេះខ្វះខាត ចំណុចគួរកែសម្រួលយកទៅពិនិត្យទៅ មិនមែនថាគេផ្ដល់ឱ្យល្អឥតខ្ចោះគ្រប់ទេ ប៉ុន្តែត្រូវតែគិត កុំទាត់ចោលបច្ចេកទេសផ្ដល់ឱ្យ យើងត្រូវយកទៅមើលដើម្បីធ្វើជាធាតុផ្សំកែសម្រួល។ កិច្ចការងារ ខ្ញុំសូមចូលរួមទៅលើចំណុច៤នេះ ដែលត្រូវយកចិត្តទុកដាក់ ជាពិសេស គឺចំណុចទី២ ក្នុងការរៀបចំយន្តការ និងរបៀបរបបការងាររបស់យន្តការដែលជាសេនាធិការ ខាងអធិការកិច្ច

និងសវនកម្មរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន ។ ពួកយើងរៀបចំកម្លាំងត្រូវ រៀបចំប្រព័ន្ធការងារត្រូវ ជួយយើងច្រើនណាស់ មានតួនាទីភារកិច្ចច្បាស់លាស់ ចែកតំបន់គ្នាច្បាស់លាស់ ប្រទាក់ក្រឡាគ្នា កាន់តែជួយថែមទៀតទៅក្នុងការអនុវត្ត វាបង្កើតភាពធន់ និងចិរភាពនៃការងារ។ ប្រសិទ្ធភាព និងចិរភាពបានន័យថាម៉ិច? នៅពេលដែលយើងបង្កើតការងារហើយ ប្រព័ន្ធការងារច្បាស់លាស់ហើយ គឺអត់ពឹងទៅលើបុគ្គលទៀតទេ។ អត់ពឹងតែថ្ងៃមុនទាល់ប្រធានស្ថាប័នអធិការកិច្ចហ្នឹង គាត់មានទម្ងន់បាននិយាយមួយគេចុះ ឥឡូវអ្នកថ្មីមកអត់សូវមានទម្ងន់អត់ចូល អត់ទេបើគ្រប់គ្នាដឹងតួនាទីភារកិច្ចអត់អាស្រ័យទៅលើបុគ្គលទៀតទេ។ យើងចង់ឱ្យប្រព័ន្ធការងារយើងអត់ផ្អែកទៅលើបុគ្គល ឥទ្ធិពលបុគ្គលគួរតែផ្អែកទៅលើភាពឯកភាពគ្នាទៅលើប្រព័ន្ធការងារ អញ្ចឹងឱ្យមនុស្សមានប្រព័ន្ធការងារ តែប្រព័ន្ធការងារព្រមានមនុស្សបាន គឺយើងមានស្តង់ដាប្រតិបត្តិមួយ អេត្យូពីមួយដែលថាឯកភាពគ្នាផ្អែកទៅលើច្បាប់ ផ្អែកលើបទដ្ឋានការងារដែលមាននិរន្តរភាព។ យើងអាចនិយាយភាសាតែមួយ ភាសាអធិការកិច្ច ឬភាសាសវនកម្ម គ្រប់ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ យើងនិយាយភាសាតែមួយអាចយល់គ្នា។ នេះហើយ គឺជានិរន្តរភាពនៃការកំណែទម្រង់ដែលយើងចាប់បាន ហើយ២០២៤ ខ្ញុំសង្ឃឹមថាយើងអាចធ្វើបានច្រើន នេះគឺជាការងារពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ជាថ្មីម្តងទៀត** ខ្ញុំសូមកោតសរសើរចំពោះសមិទ្ធផលការងារដែលក្រសួងអធិការកិច្ចសម្រេចបាន ហើយសូមលើកទឹកចិត្តថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់របស់ក្រសួង ស្ថាប័ន បំពេញតួនាទីជាភ្នែក ជាត្រចៀករបស់ថ្នាក់ដឹកនាំនៃរាជរដ្ឋាភិបាល និងជាមិត្តរបស់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ប្រកបដោយស្មារតីបុរេសកម្ម សាមគ្គីភាព វិជ្ជាជីវៈខ្ពស់ និងសហថាមពលស្របតាមអភិក្រម «ជវភាពនៃប្រព័ន្ធតួអង្គតែមួយ»។ ទន្ទឹមនេះ ខ្ញុំសូមលើកទឹកចិត្តដល់គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ភាគីពាក់ព័ន្ធទាំងអស់ ត្រូវផ្តល់កិច្ចសហការជាមួយមន្ត្រីអធិការកិច្ចក្នុងការត្រួតពិនិត្យ វាយតម្លៃក៏ដូចជាការទទួលយកអនុសាសន៍កែលម្អ។

ជាទីបញ្ចប់ ជាមួយនឹងការប្រកាសបិទ«**សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤**» របស់ក្រសួងអធិការកិច្ច ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គពិធីទាំងមូល សូមប្រកបដោយពុទ្ធពរទាំង ៥ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ បដិភានៈ កុំបីឃ្លៀងឃ្លាត៕